ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៧៥ | លោក **តាន់ ចាន់តារ៉ា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |
| ៧៦ | លោក **កែប វណ្ណៈ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ១៤ |

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រស.១៤០១.០៦០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៤*

លេខៈ ៧០ ស.ណ
**សំណៅដើមបានចម្លងជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៤**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០១១៤/០៥៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ដំឡើងថ្នាក់តាមសញ្ញាបត្រក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការ ចំនួន ០៤ រូប :

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ ថ្នាក់ចាស់ | ឋានន្តរស័ក្តិ ថ្នាក់ថ្មី |
|---|---|---|---|
| ១ | លោក សុខ ហេង | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ២ | លោក តុង សេង | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៣ | លោក នូ នឹម | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៤ | លោក សុខ លុ | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | ទៅជា ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការស. ១៤០១. ០៥៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤

លេខ: ៨៩ ស.ណ
**សំណៅចែលមានចុតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មករា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៤/០៥៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្ទេរក្របខណ្ឌលោក **អ៊ុំ ចាន់ធួត** ឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ១២ ក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ មកជានាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ដោយរក្សាមុខតំណែងនៅក្នុងក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤.១៤០១.០៦៣

លេខ: ៥៤ ស.ណ
**សំណៅដែលម្ចាស់ត្រឹមត្រូវជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ... ៧ ខែ មករា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤

# ព្រះរាជក្រឹត្យ

នស/រកត/០១១៤/០៥៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចប់មុខដំណែងឯកឧត្តម ពូ សុធីរៈ ពីរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ករស.១៤០១.០៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

លេខៈ ៨៦ ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើមសម្រាប់ចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១៤/០៥៩

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០១ ស្ដីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង **ឯកឧត្តម ហេង រតនា** ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២:** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៤០១.០១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤

លេខ: ៤២ ស.ណ
**សំណៅចម្លងចេញតាមច្បាប់ដើម**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១.៨៨២,៥៤ ហិកតា នៅក្រុងសំរោង ខេត្តឧត្តរមានជ័យ ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងកាត់ចេញពីដីដែលមានដីកាដកហូត (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន រៀលគ្រីន) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំង ការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈបានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ២៥៤៥ ខជ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៥៤៦ ខជ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ១.៨៨២,៥៤ ហិកតា ក្នុងនោះ (១) ទំហំ ៦៣៤,០៨ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និង (២) ទំហំ ១.២៤៨,៤៦ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូត (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វៀលគ្រីន) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែលទំហំ ៩៩០,៧៩ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងទំហំ ៨៩១,៧៥ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនា-សម្ព័ន្ធរូបវន្ត នៅភូមិគោកអំពិល សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិ

ជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែ នៅភូមិគោកអំពិល សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៥៥៤ ក្បាលដី ជូនប្រជាពលរដ្ឋ ២៦៦ គ្រួសារ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការកាត់ដីសរុបទំហំ ១៨៨២.៥៤ ហិកតា នៅក្រុងសំរោង ខេត្តឧត្តរមានជ័យក្នុងនោះកាត់ចេញពីដី តម្រប់ព្រៃឈើ ឆ្នាំ២០០២ និង ដីដែលមានដីកាដកហូត ( អតីតដីសម្បទានសេដ្ឋកិច្ច របស់ក្រុមហ៊ុនវៀលហ្វ្រីន) និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី**




វាស់វែងដោយឧបករណ៍ GPS Map 62s **តារាងនិយាមកា** Projection UTM Zone 48N, Datum WGS84

| ID | X_Point | Y_Point | ID | X_Point | Y_Point | ID | X_Point | Y_Point | ID | X_Point | Y_Point | ID | X_Point | Y_Point | ID | X_Point | Y_Point |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 343584 | 1592325 | 16 | 348549 | 1590199 | 31 | 347972 | 1587985 | 46 | 346014 | 1588328 | 61 | 345204 | 1588451 | 76 | 344669 | 1588622 |
| 2 | 348117 | 1592328 | 17 | 348553 | 1590094 | 32 | 346359 | 1588106 | 47 | 346037 | 1588375 | 62 | 345173 | 1588447 | 77 | 344578 | 1588637 |
| 3 | 348077 | 1591310 | 18 | 348585 | 1589980 | 33 | 346358 | 1588106 | 48 | 345880 | 1588447 | 63 | 345049 | 1588444 | 78 | 344454 | 1588596 |
| 4 | 348324 | 1591159 | 19 | 348809 | 1589885 | 34 | 346366 | 1588243 | 49 | 345842 | 1588447 | 64 | 345001 | 1588453 | 79 | 344414 | 1588595 |
| 5 | 348488 | 1591164 | 20 | 348857 | 1589879 | 35 | 346393 | 1588247 | 50 | 345828 | 1588389 | 65 | 345010 | 1588478 | 80 | 344359 | 1588606 |
| 6 | 348509 | 1591070 | 21 | 348912 | 1589856 | 36 | 346414 | 1588287 | 51 | 345821 | 1588372 | 66 | 344973 | 1588488 | 81 | 344370 | 1588675 |
| 7 | 348592 | 1590964 | 22 | 348874 | 1589751 | 37 | 346325 | 1588316 | 52 | 345734 | 1588367 | 67 | 344973 | 1588487 | 82 | 343671 | 1588804 |
| 8 | 348642 | 1590898 | 23 | 348813 | 1589677 | 38 | 346258 | 1588315 | 53 | 345743 | 1588401 | 68 | 344954 | 1588500 | 83 | 343673 | 1590268 |
| 9 | 348642 | 1590810 | 24 | 348754 | 1589539 | 39 | 346229 | 1588296 | 54 | 345718 | 1588428 | 69 | 344886 | 1588499 | 84 | 343655 | 1590533 |
| 10 | 348644 | 1590742 | 25 | 348853 | 1589199 | 40 | 346224 | 1588262 | 55 | 345718 | 1588449 | 70 | 344815 | 1588510 | 85 | 343727 | 1590798 |
| 11 | 348621 | 1590683 | 26 | 348541 | 1589283 | 41 | 346209 | 1588264 | 56 | 345661 | 1588446 | 71 | 344812 | 1588496 | 86 | 343595 | 1591921 |
| 12 | 348610 | 1590622 | 27 | 348518 | 1589118 | 42 | 346184 | 1588269 | 57 | 345573 | 1588412 | 72 | 344784 | 1588498 | 87 | 343596 | 1591922 |
| 13 | 348568 | 1590453 | 28 | 348475 | 1588976 | 43 | 346128 | 1588272 | 58 | 345549 | 1588409 | 73 | 344757 | 1588499 | 88 | 343584 | 1592325 |
| 14 | 348572 | 1590361 | 29 | 348317 | 1589018 | 44 | 346098 | 1588291 | 59 | 345518 | 1588404 | 74 | 344724 | 1588583 | | | |
| 15 | 348559 | 1590282 | 30 | 348009 | 1588905 | 45 | 346072 | 1588299 | 60 | 345316 | 1588455 | 75 | 344692 | 1588612 | | | |

៣៤២០០០ ៣៤៤០០០ ៣៤៦០០០ ៣៤៨០០០ ៣៥០០០០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី

## ការកាត់ដីទំហំ ១.១៧៣ ហិកតា នៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីរដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហុង អាហរណ៍នីហរណ៍ និងអភិវឌ្ឍដំណាំកសិឧស្សាហកម្ម និងកែច្នៃ) និង កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ព្រមទាំង ការផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិ-បុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១០០៦ ខបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១០១១ ខបប ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- លិខិតលេខ ១១៧១ ខបប ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីទំហំ ១.១៧៣ ហិកតា ក្នុងនោះ (១) ទំហំ ១៣,៥ ហិកតា កាត់ចេញពីដីរដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហាង អាហារណ៍នីហារណ៍ និងអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ) និង (២) ទំហំ ១.១៥៩,៥ហិកតា កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ស្រុកកំរៀង ខេត្តបាត់ដំបង ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១៩២ ហិកតា កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិកណ្តាល ឃុំអូរដា
- ផ្ទៃដីទំហំ ៣៩៦ ហិកតា កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិថ្មីឃុំអូរដា
- កាត់ផ្ទៃដីសរុបទំហំ ៥៨៥ ហិកតា ក្នុងនោះ: (១) ទំហំ ១៣,៥ ហិកតា កាត់ចេញពីដីរដ្ឋ (អតីតដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន លាង ហួហាង អាហារណ៍នីហារណ៍ និងអភិវឌ្ឍ

ដំណាំកសិ-ឧស្សាហកម្ម និងកែច្នៃ) និង (២) ទំហំ ៥៧១,៥ ហិកតា កាត់ចេញពីដីគម្រប ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិ កំពង់ចម្លងក្រោម ឃុំតាក្រី

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកា ដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃ (១ &២ )អនុក្រឹត្យនេះ ។

**មាត្រា ២:** ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូន ប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកកំរៀង ខេត្តបាត់ដំបង ។

**មាត្រា ៣:** ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៩៦៤ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជា កម្មសិទ្ធិលើដីឯកជន ៩៦២ ក្បាលដី ជូនប្រជាពលរដ្ឋ ៥៥៧ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) នៅស្រុក កំរៀង ខេត្តបាត់ដំបង ដែលស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

១. ឃុំអូរដា

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២៨៩ ក្បាលដី ជូនប្រជាពលរដ្ឋ ១៧០ គ្រួសារ នៅភូមិថ្មី
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២០៩ ក្បាលដី ជូនប្រជាពលរដ្ឋ ១០៤ គ្រួសារ នៅ ភូមិកណ្តាល ។

២. ឃុំតាក្រី

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៤៦៦ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើ ដីឯកជន ៤៦៤ ក្បាលដី ជូនប្រជាពលរដ្ឋ ២៨៣ គ្រួសារ អចលនវត្ថុរបស់វត្ត ០១ ក្បាលដី និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) នៅភូមិ កំពង់ចម្លងក្រោម ។

**មាត្រា ៤:** ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍ សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ២.៣៥៥,៥៧ ហិកតា នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្នុងនោះ កាត់ចេញពីដីដែលមានដីកាដកហូត និងកាត់ចេញពីដីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងការផ្តល់សិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិ-បុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៥៤០ ខបជ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តបន្ទាយមានជ័យ
- លិខិតលេខ ១៦០៨ ខបជ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តបន្ទាយមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ២.៣៥៥,៥៧ ហិកតា ក្នុងនោះ (១) ទំហំ ១.៨៩៥,៤៦ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូត និង (២) ទំហំ ៤៦០,១១ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដែលទំហំ ២.២៥៥,២២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១០០,៣៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ផ្លូវ, ប្រឡាយ,អូរ...) នៅសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ស្ថិតក្នុងភូមិដូចខាងក្រោម ៖

- កាត់ផ្ទៃដីសរុបទំហំ ២.០៥១,៤០ ហិកតា ក្នុងនោះ (១) ទំហំ ១.៦៣០,៤៦ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូត និង (២) ទំហំ ៤២០,៩៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ ដែលទំហំ ១៩៥៧,០២ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៩៤,៣៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិសួរិយា
- កាត់ផ្ទៃដីសរុបទំហំ ៣០៤,១៧ ហិកតា ក្នុងនោះ (១) ទំហំ ២៦៥ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូត និង (២) ទំហំ ៣៩,១៧ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ ដែលទំហំ ២៩៨,២០ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥,៩៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិថ្មសិន

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិសូរិយា និងភូមិថ្មសិន សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៥៧៨ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៥៧១ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៥១ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៧ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី ដីត្រពាំង ០៥ ក្បាលដី និងដីទួលរូមភូមិ ០១ ក្បាលដី) នៅសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលក្នុងនោះផ្តល់ជា៖

- កម្មសិទ្ធិលើក្បាលដីសរុប ៤៨២ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៤៧៥ ក្បាលដី ជូនប្រជាពលរដ្ឋ ២៨១ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៧ ក្បាលដី (ដីសាលារៀន ០១ ក្បាលដី ដីត្រពាំង ០៥ ក្បាលដី និងដីទួលរូមភូមិ ០១ ក្បាលដី) នៅភូមិសូរិយា
- កម្មសិទ្ធិលើក្បាលដី ៩៦ ក្បាលដី ជូនប្រជាពលរដ្ឋ ៧០ គ្រួសារ នៅភូមិថ្មសិន ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល៖*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីសរុបទំហំ ៤.០៥០,៧០ ហិកតា នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្នុងនោះ កាត់ចេញពីដីគម្របព្រៃឈើ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទឹមវ៉េង រ៉ាប់បើរ ក្រុមហ៊ុន ដាតាវ៉ាប់បើរ និងក្រុមហ៊ុនឃុន សៀ អ៊ិមផត អ៊ិចផត សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈបានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត ១១២៥ ឧជ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- លិខិត ២៥០៦ ឧជ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ៤.០៥០,៧០ ហិកតា ក្នុងនោះ (១) ទំហំ ៦៨៨,២៣ ហិកតា កាត់ចេញពីដីគម្របព្រៃឈើ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (២) ទំហំ ១.៩២៥,៣៨ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ទឹមវីង រ៉ាប់ប័រ (៣) ទំហំ ១.១២២,៥៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដាតារ៉ាប់ប័រ និង (៤) ទំហំ ៣១៤,៥៩ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ឃុន សៀ អ៊ិមផតអ៊ិចផត សម្រាប់ធ្វើប្រទានកម្ម ទំហំ ៣.២៧២,០៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៧៧៨,៦៦ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិទួលគ្រួស ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាផូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិទួលគ្រួស ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

**មាត្រា ៣**: ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១.១១៩ ក្បាលដី ជូនប្រជាពលរដ្ឋ ៧១៤ គ្រួសារ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ ១

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៣២ អនក្រ.បក...ចុះថ្ងៃទី...២០...ខែ...មករា...ឆ្នាំ ២០១៤ ស្តីពីការកាត់ដីសរុបទំហំ ៤០៥០.៧០ ហិកតា នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ក្នុងនោះកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ កាត់ចេញពីដីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនទីមរីងរ៉ាប់ប៊័រ ក្រុមហ៊ុន ដាតារ៉ាប់ប៊័រ និងក្រុមហ៊ុនឃុនសៀ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១០៧៦ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ក្រមសីលធម៌ឱសថការី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៦/០២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧ /០៣៧ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រនិងជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការបង្កើតគណៈឱសថការីកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែមករា ឆ្នាំ២០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ ការគោរពច្បាប់ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ ប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរដើម្បីសុខុមាលភាពប្រជាជន។

**មាត្រា២ ..**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីក្រមសីលធម៌វិជ្ជាជីវៈឱសថសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះឱសថការីទាំងអស់ដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈឱសថសាស្ត្រពីក្រសួងសុខាភិបាល។

**មាត្រា៤ ..**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម៖

**ការប្រកបវិជ្ជាជីវៈឱសថសាស្ត្រ** សំដៅដល់ការប្រកបវិជ្ជាជីវៈទាក់ទងនឹងការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ការទុកដាក់ថែរក្សា ការផលិត ការចែកចាយ អាហរណកម្មនីហរណកម្ម ការត្រួតពិនិត្យគុណភាព ការធ្វើពាណិជ្ជកម្មនិងការផ្សព្វផ្សាយឱសថ ឧបករណ៍បរិក្ខារពេទ្យ ប្រតិករ ផលិតផលគ្រឿងសម្អាង និងការប្រកបវិជ្ជាជីវៈទាក់ទងនឹងមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ។

**ការផ្តល់ឱសថ** សំដៅដល់សកម្មភាពផ្តល់ឱសថដោយមានការពន្យល់ច្បាស់លាស់ដល់អ្នកជំងឺឬអតិថិជន។

**គ្រឹះស្ថានឱសថ** សំដៅដល់កន្លែងដែលឱសថការីបម្រើការងារឬទទួលខុសត្រូវ ដូចជាគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលឱសថ គ្រឹះស្ថាននាំចូលនិងចែកចាយឱសថ គ្រឹះស្ថាននាំចេញឱសថ គ្រឹះស្ថានលក់ដុំឱសថ ឱសថស្ថាននិងឱសថស្ថានរង។

**ឱសថការី** សំដៅដល់នីតិជនដែលមានសញ្ញាបត្រឱសថសាស្ត្រ ចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រឱសថសាស្ត្រ ចេញដោយគ្រឹះស្ថានឧត្តមសិក្សាដែលបានទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

## ជំពូកទី២

## ករណីយកិច្ចទូទៅរបស់ឱសថការី

**មាត្រា៥ ..**

ឱសថការីត្រូវប្រកាន់ខ្ជាប់នូវករណីយកិច្ចការពារសុខភាពសាធារណៈដោយត្រូវគោរពជីវិតរាងកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

**មាត្រា៦ ..**

ឱសថការីត្រូវប្រកាន់ខ្ជាប់នូវឯករាជ្យភាពវិជ្ជាជីវៈ និងត្រូវធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងវិជ្ជាជីវៈឱសថសាស្ត្រ អមវេជ្ជសាស្ត្រ ដោយគោរពដាច់ខាតនូវសុចរិតភាព ភក្តីភាពនិងឯករាជ្យភាពវិជ្ជាជីវៈ ដោយគ្មានការបង្ខិតបង្ខំពីខាងក្រៅ ទោះបីជាស្ថិតក្នុងលក្ខខណ្ឌបែបណាក៏ដោយ។

**មាត្រា៧ ..**

ឱសថការីត្រូវតែចូលរួមរាល់សកម្មភាពដែលតម្រូវដោយអាជ្ញាធរសុខាភិបាលដើម្បីសុខុមាលភាពប្រជាជននិងសង្គម។

**មាត្រា៨ ..**

ទោះក្នុងរូបភាពអ្វីក៏ដោយ ឱសថការីមិនត្រូវបង្កនូវអំពើដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈឡើយ។ ឱសថការីត្រូវចូលរួមប្រឆាំងនឹងអំពើឆបោក ពិសេសត្រូវជៀសវាងផលិត ចែកចាយ និងធ្វើអាជីវកម្មនូវផលិតផលឱសថក្លែងក្លាយនិងអន់គុណភាព ហួសកំណត់ពេលប្រើប្រាស់ ឬមិនឱ្យប្រើប្រាស់។

**មាត្រា៩ ..**

ឱសថការីត្រូវផ្តល់ដំណឹងជូនគណៈឱសថការីកម្ពុជាអំពីការបើក ការបិទ ការប្តូរទីតាំង ការប្តូរឱសថការីទទួលខុសត្រូវ ការប្តូរម្ចាស់ទុន ការផ្អាកឬការឈប់ប្រកបអាជីវកម្ម ឬការឈប់ទទួលខុសត្រូវគ្រឹះស្ថានឱសថ។

**មាត្រា១០ ..**

នៅពេលសុំចុះឈ្មោះក្នុងបញ្ជីគណៈឱសថការីកម្ពុជា ឱសថការីត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរថាខ្លួនបានអានក្រមសីលធម៌ឱសថការី និងសន្យាគោរពប្រតិបត្តិតាម។

**មាត្រា១១ ..**

ឱសថការីត្រូវចូលរួមក្នុងសកម្មភាពវិជ្ជាជីវៈដែលរៀបចំដោយគណៈឱសថការីកម្ពុជា។

**មាត្រា១២ ..**

ឱសថការីដែលគ្រប់គ្រងគ្រឹះស្ថានឱសថឬមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ ត្រូវរៀបចំទីកន្លែងទាំងខាងក្រៅ ទាំងខាងក្នុង ឱ្យសមស្របទៅតាមបទដ្ឋានបច្ចេកទេស ដើម្បីធានាការបម្រើនិងការផ្តល់សេវាសមស្របប្រកបដោយគុណភាព។

**មាត្រា១៣ ..**

ឱសថការីត្រូវបំពេញគ្រប់សកម្មភាពនៃវិជ្ជាជីវៈដោយយកចិត្តទុកដាក់និងប្រុងប្រយ័ត្នជានិច្ចដោយគោរពឱ្យបានខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិនិងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈឱសថសាស្ត្រ។ ទោះបីជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ឱសថការីត្រូវប្រកាន់ឥរិយាបថទៀងត្រង់និងថ្លៃថ្នូរ។ ឱសថការីត្រូវជៀសវាងរាល់អំពើទាំងឡាយណាដែលនាំឱ្យអាប់ឱនដល់វិជ្ជាជីវៈរបស់ខ្លួន ទោះបីជាមិនស្ថិតក្នុងពេលបំពេញមុខងារវិជ្ជាជីវៈឱសថសាស្ត្រក៏ដោយ។

**មាត្រា១៤ ..**

ឱសថការីមានកាតព្វកិច្ចលើកកម្ពស់ចំណេះដឹងផ្នែកឱសថសាស្ត្រ ធ្វើឱ្យកាន់តែសុក្រឹតនូវចំណេះវិជ្ជារបស់ខ្លួនស្របតាមបច្ចុប្បន្នភាពនៃការវិវឌ្ឍបច្ចេកទេសវិទ្យាសាស្ត្រ ពិសេសត្រូវចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលបន្តក្នុងវិស័យសុខាភិបាល ដែលទទួលស្គាល់ដោយគណៈឱសថការីកម្ពុជា។

**មាត្រា១៥ ..**

រាល់ការចុះកិច្ចសន្យា កិច្ចព្រមព្រៀងការងារ ឬអនុស្សរណៈនៃការងារជាមួយសមាគម ដៃគូអភិវឌ្ឍ និង អង្គភាពផលិតកម្ម ពាណិជ្ជកម្ម ផ្សព្វផ្សាយឬព័ត៌មានឱសថ ចែកចាយឱសថ និងអ្នក[illegible] សុខភាពជាដើម ឱសថការី ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

**មាត្រា១៦ ..**

ឱសថការីមិនត្រូវទទួលប្រាក់រង្វាន់ការងារ បើការទទួលប្រាក់រង្វាន់នោះធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យក្នុងការអនុវត្តការងាររបស់ខ្លួនទាក់ទងនឹងគុណភាពឱសថឬដល់គុណភាពនៃសេវា។ ការទទួលយកឬស្នើសុំ ឬដាក់កំហិតនូវលាភការដោយមិនសមាមាត្រទៅនឹងទំហំការងារនិងការទទួលខុសត្រូវរបស់ខ្លួនត្រូវបានហាមឃាត់។

**មាត្រា១៧ ..**

ឱសថការីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់សកម្មភាពទាំងឡាយណាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ទោះបីជាសកម្មភាពនោះប្រព្រឹត្តដោយសហការីរបស់ខ្លួនក៏ដោយ និងត្រូវធ្វើយ៉ាងណាឱ្យបុគ្គលិកក្រោមឱវាទគោរពតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងកាតព្វកិច្ចនិងករណីយកិច្ច ដែលមានចែងក្នុងអនុក្រឹត្យនេះ។

**មាត្រា១៨ ..**

នៅតាមគ្រឹះស្ថានឱសថ ឱសថការីដែលជាអ្នកគ្រប់គ្រងត្រូវធានាថាឱសថការីជំនួយការឬឱសថការីជំនួសបានចុះឈ្មោះក្នុងបញ្ជីគណៈឱសថការី។ ឱសថការីជំនួយការឬឱសថការីជំនួស និងបុគ្គលិកក្រោមឱវាទទាំងអស់ ត្រូវមានការលះបង់ដោយភក្តីភាពក្នុងការងារ។

**មាត្រា១៩ ..**

ឱសថការីដែលបម្រើការក្នុងគ្រឹះស្ថានឱសថនិងមន្ទីរពិសោធន៍អមវេជ្ជសាស្ត្ររបស់រដ្ឋឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលសម្រាប់ការធ្វើកម្មសិក្សា ត្រូវយកចិត្តទុកដាក់ដូចខាងក្រោម៖

- មានពេលវេលាគ្រប់គ្រាន់ជួយបង្ហាត់បង្ហាញ
- មានមូលដ្ឋានអនុវត្តរួមនិងសកម្មភាពជាក់ស្តែងសម្រាប់ការបង្ហាត់បង្ហាញ
- ណែនាំនិស្សិតឱ្យយល់អំពីតម្លៃវិជ្ជាជីវៈនិងការគោរពក្រមសីលធម៌
- ណែនាំនិស្សិតឱ្យស្វែងយល់និងគោរពកាតព្វកិច្ចទាំងឡាយដូចគ្នានឹងឱសថការីរបស់គ្រឹះស្ថាន
- វាយតម្លៃនិស្សិតដែលធ្វើកម្មសិក្សាដោយសុចរិតនិងមានមូលដ្ឋានត្រឹមត្រូវ។

**មាត្រា២០ ..**

ឱសថការីគួរប្រើទុនផ្ទាល់ខ្លួនក្នុងការប្រកបសេវាកម្មឬអាជីវកម្មឱសថនិងសេវាកម្មអមវេជ្ជសាស្ត្រជាជាងការទទួលខុសត្រូវផ្នែកបច្ចេកទេសឱ្យម្ចាស់ទុន។

**មាត្រា២១ ..**

ឱសថការីត្រូវតែគោរពតាមគោលការណ៍នៃការអនុវត្តល្អដែលបានកំណត់សម្រាប់ផ្នែកវិជ្ជាជីវៈនីមួយៗ និងមិនត្រូវឱ្យធ្លាក់ទៅក្នុងឧបាយកលពាណិជ្ជកម្មដែលនាំឱ្យប៉ះពាល់កិត្យានុភាពវិជ្ជាជីវៈឱសថសាស្ត្រនោះឡើយ។

**មាត្រា២២ ..**

ឱសថការីត្រូវចូលរួមនិងលើកកម្ពស់កសាងប្រព័ន្ធបរិស្ថានល្អ ដោយជៀសវាងរាល់ទង្វើដែលបង្កឱ្យខូចបរិស្ថាន ពិសេសត្រូវចូលរួមក្នុងសកម្មភាពប្រមូលនិងបំផ្លាញចោលឱសថក្លែងក្លាយ ខូចគុណភាព អន់គុណភាព ហួសកំណត់ពេលប្រើប្រាស់ ឬមិនឱ្យប្រើប្រាស់។

**មាត្រា២៣ ..**

ឱសថការីត្រូវរក្សាទំនាក់ទំនងល្អ ដោយការជឿទុកចិត្តជាមួយភ្នាក់ងារមានសមត្ថកិច្ច និងត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចឬបេសកកម្មរបស់ភ្នាក់ងារត្រួតពិនិត្យឱសថឬអធិការកិច្ចឱសថ។

## ជំពូកទី៣
## ករណីយកិច្ចដោយឡែករបស់ឱសថការី

**មាត្រា២៤ ..**

ឱសថការីមានសិទ្ធិទទួលខុសត្រូវគ្រប់គ្រងបច្ចេកទេស ក្នុងការប្រកបវិជ្ជាជីវៈឱសថសាស្ត្របានតែមួយកន្លែងគត់។

ការប្រកបវិជ្ជាជីវៈឱសថសាស្ត្រមានវិសមិតភាពជាមួយនឹងការប្រកបវិជ្ជាជីវៈសុខាភិបាលដទៃទៀត ទោះបីជាឱសថការីមានសញ្ញាបត្រវិជ្ជាជីវៈនោះក៏ដោយ។

**មាត្រា២៥ ..**

ឱសថការីត្រូវរៀបចំផ្លាកនិងឈ្មោះឱសថស្ថានឱ្យបានសមរម្យនិងងាយយល់សម្រាប់អតិថិជន។ នៅលើផ្លាកត្រូវមានឈ្មោះអ្នកទទួលខុសត្រូវនិងអាសយដ្ឋាន។

**មាត្រា២៦ ..**

សកម្មភាពពិនិត្យ ពិគ្រោះ ព្យាបាលជំងឺនៅក្នុងឱសថស្ថាន ព្រមទាំងការដាក់ផ្លាកពិនិត្យ ព្យាបាលនៅឱសថស្ថាន ត្រូវបានហាមឃាត់។

**មាត្រា២៧ ..**

ឱសថការីមានកាតព្វកិច្ចៈ

- មានវត្តមាននៅឱសថស្ថានក្នុងម៉ោងធ្វើការឬក្នុងម៉ោងដែលតម្រូវដោយក្រសួងសុខាភិបាល ឬគណៈឱសថការី
- រកអ្នកជំនួសតាមច្បាប់កំណត់ក្នុងករណីអវត្តមាននៅឱសថស្ថាន
- ត្រូវចូលរួមក្នុងកម្មវិធីយាមយប់និងថ្ងៃឈប់សម្រាករបស់ឱសថស្ថាន ដែលរៀបចំឡើងដោយមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬក្រុមប្រឹក្សាគណៈឱសថការីរាជធានី ខេត្ត
- គោរពតាមគោលការណ៍និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលបានកំណត់សម្រាប់ឱសថស្ថានយាម
- ផ្សព្វផ្សាយឱ្យសាធារណជនបានដឹងអំពីកម្មវិធីឱសថស្ថានយាម។

**មាត្រា២៨ ..**

អ្នកគ្រប់គ្រងឱសថស្ថានរបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការ ត្រូវតែជាឱសថការីដែលបានចុះឈ្មោះក្នុងបញ្ជីសមាជិកគណៈឱសថការីកម្ពុជា។

ឱសថការីដែលបម្រើការងារនៅក្នុងឱសថស្ថានរបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការ បម្រើតែសេវារបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការខ្លួនតែប៉ុណ្ណោះ។

**មាត្រា២៩ ..**

ឱសថការីគ្រប់គ្រងឱសថស្ថានរបស់មន្ទីរពេទ្យរដ្ឋ ឬឯកជន ឬអង្គការ មានភារកិច្ចដឹកនាំលើការផ្គត់ផ្គង់ ការផ្សំឱសថ ការទុកដាក់ ការត្រួតពិនិត្យ និងការចែកចាយផលិតផលសុខាភិបាល ព្រម[illegible]

ការងារទាក់ទងនឹងគុណភាព សុវត្ថិភាពនៃការព្យាបាល ការសិក្សាគ្លីនិក ការតាមដានអំពីផលរំខានរបស់ឱសថ និងការប្រមូលឱសថដែលខូចគុណភាពពីទីផ្សារ។

**មាត្រា៣០ ..**

ឱសថការីត្រូវផ្តល់ឱសថដោយគោរពតាមវេជ្ជបញ្ជាឬតាមសំណើរបស់អ្នកជំងឺ ដោយគិតពីផលប្រយោជន៍នៃសុខភាពជាចម្បង និងត្រូវប្រាប់អ្នកជំងឺឱ្យទៅពិគ្រោះជាមួយគ្រូពេទ្យក្នុងករណីចាំបាច់។ ឱសថការីត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាកុំឱ្យយកស្ថានភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបុគ្គលិកលក្ខណៈនៃអ្នកជំងឺឬប្រភេទនៃឱសថជាឧបសគ្គក្នុងការផ្តល់ឱសថ។

**មាត្រា៣១ ..**

ក្នុងករណីចាំបាច់ឬពេលយាម ឱសថការីអាចផ្តល់ឱសថដែលអាចជំនួសគ្នាបានដល់អតិថិជន ដោយគោរពតាមបទវិធានទាំងឡាយស្តីពីការផ្តល់ឱសថជំនួស។

**មាត្រា៣២ ..**

ឱសថការីត្រូវតែពិភាក្សាជាមួយគ្រូពេទ្យដែលចេញវេជ្ជបញ្ជាជាមុនសិន នៅពេលមានចម្ងល់ឬសង្ស័យលើវេជ្ជបញ្ជាមិនច្បាស់លាស់អំពីឈ្មោះឬប្រភេទឱសថ របៀបឬកម្រិតប្រើ ផលរំខាន ឬភាពងាយមានប្រតិកម្មបណ្តាលពីឱសថឬអន្តរកម្មឱសថ។

**មាត្រា៣៣ ..**

ឱសថការីត្រូវធានាលើសកម្មភាពផ្តល់ឱសថដល់អ្នកជំងឺ ដោយផ្សារភ្ជាប់៖

- ការវិភាគឱសថលើវេជ្ជបញ្ជា
- ការរៀបចំឱសថសម្រាប់អ្នកជំងឺឱ្យសមស្របតាមគោលការណ៍អនុវត្តល្អក្នុងឱសថស្ថានដែលកំណត់ដោយក្រសួងសុខាភិបាល
- ផ្តល់ព័ត៌មាននិងដំបូន្មានចាំបាច់សម្រាប់ការប្រើប្រាស់ឱសថបានត្រឹមត្រូវ ដូចជាប្រសិទ្ធភាព ការហាមប្រើ ផលរំខាន ប្រការគួរយកចិត្តទុកដាក់ កម្រិតប្រើដោយការពន្យល់នេះមិនធ្វើឱ្យប៉ះពាល់ដល់ការជឿទុកចិត្តទៅលើគ្រូពេទ្យសាមីឡើយ។

**មាត្រា៣៤ ..**

ក្នុងករណីដែលអ្នកជំងឺប្រើឱសថដោយចិត្តឯង ឱសថការីត្រូវជំទាស់ទៅនឹងការរំលោភលើការប្រើឱសថ ហើយត្រូវប្រាប់អ្នកជំងឺអំពីផលវិបាកអវិជ្ជមាននិងណែនាំឱ្យទៅពិគ្រោះជាមួយគ្រូពេទ្យក្នុងករណីចាំបាច់។

**មាត្រា៣៥ ..**

ក្នុងក្របខ័ណ្ឌនៃការគោរពសិទ្ធិនិងផលប្រយោជន៍អ្នកជំងឺ ឱសថការីត្រូវពន្យល់ ផ្តល់ដំបូន្មានចំពោះឱសថណាដែលខ្លួនយល់ដឹង។ ដើម្បីស្វែងយល់លើឱសថណាមួយ ឱសថការីមិនត្រូវពឹងផ្អែកតែទៅលើឯកសារចេញពីគ្រឹះស្ថានផលិតឱសថឡើយ។

**មាត្រា៣៦ ..**

ឱសថការីត្រូវទទួលខុសត្រូវនិងធានាចំពោះការចែកចាយឱសថដោយខ្លួនឯងឬដោយបុគ្គលជំនួយ ដោយបំពេញឱ្យបានត្រឹមត្រូវតាមគោលការណ៍នៃការអនុវត្តល្អក្នុងការផ្តល់ឱសថ។

**មាត្រា៣៧** .-

ផ្លាកមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រឯកជន ត្រូវមានឈ្មោះឱសថការីដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងបច្ចេកទេស។

**មាត្រា៣៨** .-

ឱសថការីនៃមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ មិនត្រូវធ្វើការវិភាគដែលមិនចាំបាច់ដើម្បីទាញប្រយោជន៍ពីអតិថិជនឡើយ។ ឱសថការីនៃមន្ទីរពិសោធន៍អមវេជ្ជសាស្ត្រ អាចបដិសេធដោយមានការពន្យល់ មិនធ្វើការវិភាគឬសម្រង់វត្ថុវិភាគ ប្រសិនបើនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អតិថិជន ឬសំណើសុំវិភាគឬសម្រង់វិភាគនោះមានលក្ខណៈខុសច្បាប់។

**មាត្រា៣៩** .-

ការផលិត ការនាំចូល ការនាំចេញ ការលក់ដុំឱសថ ឧបករណ៍បរិក្ខារពេទ្យ និងប្រតិករ ដែលប្រព្រឹត្តនៅក្នុងឬតាមរយៈគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលឱសថ គ្រឹះស្ថាននាំចូលនិងចែកចាយឱសថ គ្រឹះស្ថាននាំចេញឱសថ និងគ្រឹះស្ថានលក់ដុំឱសថ ត្រូវតែស្ថិតក្រោមការទទួលខុសត្រូវរបស់ឱសថការី។

**មាត្រា៤០** .-

ការលក់ដុំឱសថ ឧបករណ៍បរិក្ខារពេទ្យ និងប្រតិករដល់សេវាសុខាភិបាលដែលគ្មានច្បាប់អនុញ្ញាត ឬការចែកចាយមិនត្រឹមត្រូវតាមប្រព័ន្ធដែលកំណត់ដោយក្រសួងសុខាភិបាលឬដោយគណៈឱសថការីកម្ពុជា ត្រូវបានហាមឃាត់ជាដាច់ខាត។

**មាត្រា៤១** .-

ឱសថការីត្រូវជ្រើសរើសយកដៃគូផ្គត់ផ្គង់ឱសថ ឧបករណ៍បរិក្ខារពេទ្យ និងប្រតិករ ដោយគិតអំពីគុណភាពសេវានិងនិរន្តរភាពនៃការផ្គត់ផ្គង់។

**មាត្រា៤២** .-

ឱសថការីគ្រប់គ្រងគ្រឹះស្ថានផលិតឱសថ គ្រឹះស្ថាននាំចូលឱសថ គ្រឹះស្ថាននាំចូលនិងចែកចាយឱសថ គ្រឹះស្ថាននាំចេញឱសថ និងគ្រឹះស្ថានលក់ដុំឱសថ ជាអ្នកទទួលខុសត្រូវលើរាល់បញ្ហាបច្ចេកទេសទាក់ទងនឹងសកម្មភាពនៃគ្រឹះស្ថាននោះ រួមមានការផលិត ការចែកចាយ ការផ្សព្វផ្សាយផលិតផល ការតាមដានផលវិបាកពីឱសថ ការដកហូតឱសថពីទីផ្សារ ការនាំចូលនាំចេញ ការរក្សាទុកក្នុងឃ្លាំងជាដើម។

**មាត្រា៤៣** .-

ឱសថការីដែលបានយល់ព្រមប្រកបវិជ្ជាជីវៈក្រោមកិច្ចសន្យាឬមានលក្ខខណ្ឌជាមួយស្ថាប័នរដ្ឋ អង្គការជាតិឬអន្តរជាតិ ឬគ្រឹះស្ថានឯកជនឬសមូហភាពណាមួយ ត្រូវប្រកាន់យកការរក្សាការសម្ងាត់និងឯករាជ្យភាពវិជ្ជាជីវៈ។

ឱសថការីមិនត្រូវទទួលឬមិនត្រូវបានបង្ខំឱ្យទទួលការដាក់កម្រិតទៅលើឯករាជ្យភាពក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនពីសំណាក់រូបវន្តបុគ្គល នីតិបុគ្គល ឬពីអង្គភាពដែលជានិយោជករបស់ឱសថការីនោះឡើយ។ ឱសថការីត្រូវបំពេញការងារដោយឱ្យអាទិភាពទៅលើផលប្រយោជន៍សុខភាព[illegible]

ព្រមទាំងទៅលើផលប្រយោជន៍និងសុវត្ថិភាពរបស់អ្នកធ្វើការនៅក្នុងសមូហភាពឬអង្គការដែលឱសថការីនោះប្រកបមុខរបរ។

**មាត្រា៤៤ .-**

ការប្រកបវិជ្ជាជីវៈឱសថសាស្ត្រទោះបីជាស្ថិតក្រោមរូបភាពអ្វីនៅឱសថស្ថាន សហគ្រាស សមូហភាព អង្គការដែលស្ថិតក្រោមសមត្ថកិច្ចនៃច្បាប់ស្ដីពីការងារក៏ដោយ ត្រូវតែធ្វើឡើងក្រោមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យានេះត្រូវកំណត់ច្បាស់លាស់អំពីកាតព្វកិច្ចរបស់ភាគីពាក់ព័ន្ធនិងត្រូវអនុវត្តតាមច្បាប់ស្ដីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវផ្ញើជូនគណៈឱសថការីកម្ពុជាមួយច្បាប់ដើម្បីជ្រាប និងតម្កល់ទុកជាឯកសារ។

**មាត្រា៤៥ .-**

ឱសថការីដែលមានប្រាក់បៀវត្ស មិនអាចទទួលប្រាក់រង្វាន់ដោយសម្អាងលើបទដ្ឋានផលិត ឬទិន្នផលផលិតកម្មឬសេវា ឬកិច្ចចាត់ចែងផ្សេងទៀតដែលបណ្ដាលឱ្យបាត់បង់ឯករាជ្យភាពនិងគុណភាពវិជ្ជាជីវៈ ឬធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃផលិតផលឬសេវា និងមានបច្ច័យមិនល្អចំពោះសុខភាពសាធារណៈឡើយ។

**មាត្រា៤៦ .-**

ការអប់រំ ឬការផ្ដល់ព័ត៌មានទូទៅ ឬការផ្សព្វផ្សាយផលិតផលឱសថជាសាធារណៈ ដោយឱសថការី ទោះបីជាក្រោមរូបភាពណាក៏ដោយ ត្រូវស្របតាមបទដ្ឋានបច្ចេកទេស ដោយឡែកការផ្សព្វផ្សាយផលិតផលឱសថ ត្រូវតែមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

**មាត្រា៤៧ .-**

នៅពេលផ្ដល់ព័ត៌មានឬអប់រំផ្សព្វផ្សាយទាក់ទងនឹងឱសថឬសុខភាពសាធារណៈ ឱសថការីត្រូវតែមានសម្អាងហេតុផលច្បាស់លាស់។ ឱសថការីត្រូវជៀសវាងការនិយាយឃោសនាជាប្រយោជន៍ផ្ទាល់ខ្លួនឬប្រយោជន៍គ្រឹះស្ថានដែលខ្លួនធ្វើការឬខ្លួនគាំទ្រ ឬសម្រាប់មូលហេតុអ្វីមួយដែលមិនមែនជាផលប្រយោជន៍សាធារណៈ ដោយប្រុងប្រយ័ត្នទៅលើប្រតិឃាតនៃពាក្យសម្ដីរបស់ខ្លួនចំពោះអ្នកស្ដាប់។

**មាត្រា៤៨ .-**

ឱសថការីដែលធ្វើការចែកចាយក្នុងបំណងផ្សព្វផ្សាយដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬគ្រឹះស្ថានដែលខ្លួនគាំទ្រនូវផលិតផលឱសថ ដែលមិនទាន់មានច្បាប់អនុញ្ញាតត្រឹមត្រូវ ត្រូវបានហាមឃាត់ ទោះបីជាការចែកចាយនោះមានប្រយោជន៍ដល់សុខភាពក៏ដោយ។

**មាត្រា៤៩ .-**

នៅពេលធ្វើបទបង្ហាញឬផ្សព្វផ្សាយឱសថ ឱសថការីត្រូវមានមូលដ្ឋានច្បាស់លាស់ក្នុងការផ្ដល់ព័ត៌មានវិទ្យាសាស្ត្រដែលទាក់ទងនឹងវេជ្ជសាស្ត្រ ឱសថសាស្ត្រ ព្រមទាំងភាពត្រឹមត្រូវនៃការប្រើប្រាស់ឱសថ ជៀសវាងការបំភ័ន្តឬបំផ្លើស។

**មាត្រា៥០ .-**

ឱសថការីត្រូវជៀសវាងការស្វះស្វែងទាក់ទាញអតិថិជន ដោយប្រើប្រាស់មធ្យោបាយដែលនាំឱ្យបាត់បង់កិត្តិយសនិងសេចក្ដីថ្លៃថ្នូរនៃវិជ្ជាជីវៈ បើទោះបីជាមធ្យោបាយទាំងនោះមិនត្រូវបានប ច្បាស់លាស់ដោយបទប្បញ្ញត្តិជាធរមានក៏ដោយ។

ឱសថការីត្រូវជៀសវាងរាល់ការប្រកួតប្រជែងមិនស្មោះត្រង់។

**មាត្រា៥១ .-**

ការផ្សព្វផ្សាយឱសថដោយឱសថការីត្រូវប្រព្រឹត្តទៅដោយភាពថ្លៃថ្នូរ គោរពផលប្រយោជន៍អ្នកជំងឺ ទៅតាមវិធាននៃការផ្សព្វផ្សាយ និងជៀសវាងប្រើមធ្យោបាយអូសទាញឱ្យប្រើឱសថ។

**មាត្រា៥២ .-**

ហាមឃាត់ចំពោះឱសថការីក្នុងការផ្តល់រង្វាន់លាភការដល់ជនណាដែលប្រកបវិជ្ជាជីវៈឱសថ-សាស្ត្រឬវេជ្ជសាស្ត្រ ឬវិជ្ជាជីវៈសុខាភិបាលដទៃទៀត ដើម្បីលើកទឹកចិត្តឬជំរុញឱ្យប្រើឱសថ។

**មាត្រា៥៣ .-**

ឱសថការីមិនត្រូវរារាំងអតិថិជនក្នុងការជ្រើសរើសគ្រឹះស្ថានសេវាកម្ម ឬអាជីវកម្មឱសថ ឬសេវាកម្មអមវេជ្ជសាស្ត្រណាដែលអតិថិជនពេញចិត្តនោះឡើយ។

ឱសថការីមិនត្រូវសម្រួលឱ្យអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលខុសច្បាប់ណាម្នាក់ឬសម្រួលឱ្យអ្នកជំងឺនូវផលប្រយោជន៍ដែលជាអំពើខុសច្បាប់ ដូចជាការបង្កើនតម្លៃក្នុងវិក្កយបត្រ ឬការចេញសេចក្តីបញ្ជាក់តម្រូវចិត្តអ្នកជំងឺ។

**មាត្រា៥៤ .-**

ឱសថការីដែលមានមុខងារក្នុងតំណែងគ្រប់ប្រភេទឬគោរមងារជាកិត្តិយសផ្សេងៗ មិនត្រូវប្រើឈ្មោះនៃមុខងារឬគោរមងារនៃកិត្តិយសនោះ ដើម្បីបង្អួតឬទាក់ទាញស្វែងរកអតិថិជនឡើយ។ ក្នុងការធ្វើអាជីវកម្មឱសថឬសេវាកម្មអមវេជ្ជសាស្ត្រ ឱសថការីអាចប្រើឈ្មោះរបស់ខ្លួន ដោយភ្ជាប់ពាក្យជាមុខងារបច្ចេកទេសវិជ្ជាជីវៈដែលទទួលបានពីគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល។

**មាត្រា៥៥ .-**

ឱសថការីត្រូវអនុវត្តតាមសន្ទស្សន៍កម្រៃដែលកំណត់ដោយក្រសួងសុខាភិបាលឬដោយគណៈឱសថការីកម្ពុជា។ ការអនុវត្តទាំងឡាយណាដែលមាននិន្នាការបញ្ចុះតម្លៃឱសថក្នុងបំណងប្រកួតប្រជែង ត្រូវបានហាមឃាត់ ប៉ុន្តែឱសថការីមានសិទ្ធិក្នុងការផ្តល់ឱសថដោយមិនយកថ្លៃ។

**មាត្រា៥៦ .-**

ឱសថការីដែលទទួលបន្ទុកត្រួតពិនិត្យនិងអធិការកិច្ចវិជ្ជាជីវៈឱសថសាស្ត្រ ត្រូវស្ថិតនៅក្នុងភាព-ឯករាជ្យនៃមុខងារ និងមិនត្រូវបានអនុញ្ញាតឱ្យត្រួតពិនិត្យនិងធ្វើអធិការកិច្ចចំពោះគ្រឹះស្ថានផ្ទាល់ខ្លួន ឬគ្រឹះស្ថានជារបស់សហព័ទ្ធ ឬជារបស់ញាតិលោហិតផ្ទាល់ ឬជារបស់ញាតិពន្ធនៅក្នុង៣(បី)ថ្នាក់រាប់ទាំងថ្នាក់ទី៣(បី)ផង ឬគ្រឹះស្ថានដែលមានទំនាក់ទំនងការងារឬផលប្រយោជន៍ជាមួយនឹងឱសថការីកំពុងជាប់ពាក់ព័ន្ធឡើយ។

**មាត្រា៥៧ .-**

ឱសថការីទទួលបន្ទុកត្រួតពិនិត្យនិងអធិការកិច្ចត្រូវ៖

- បញ្ជាក់ប្រាប់ដល់តំណាងនៃអង្គភាពដែលខ្លួនត្រួតពិនិត្យអំពីបេសកកម្មនិងអំពីក្របខ័ណ្ឌច្បាប់និងព្រំដែនកំណត់ដែលបេសកកម្មនេះត្រូវអនុវត្ត
- បំពេញភារកិច្ចមិនលម្អៀងក្នុងការធ្វើសេចក្តីសន្និដ្ឋាន

- រក្សាការសម្ងាត់ដោយមិនត្រូវធ្វើអត្ថាធិប្បាយជាសាធារណៈអំពីបេសកកម្មរបស់ខ្លួន។

## ជំពូកទី៤
## ករណីយកិច្ចចំពោះអ្នកជំងឺនិងអតិថិជន

**មាត្រា៥៨.-**

ឱសថការីត្រូវប្រកាន់ខ្ជាប់នូវអាកប្បកិរិយាត្រឹមត្រូវនិងយកចិត្តទុកដាក់ចំពោះអ្នកជំងឺនិងអតិថិជន ដោយគ្មានការរើសអើង និងត្រូវខិតខំពន្យល់ឲ្យអនុវត្តតាមវេជ្ជបញ្ជាដើម្បីឱ្យការព្យាបាលមានប្រសិទ្ធភាព។ ឱសថការីត្រូវគោរពសិទ្ធិរបស់អ្នកជំងឺក្នុងការជ្រើសរើសឱសថស្ថាននិងគោរពឆន្ទៈរបស់អ្នកជំងឺក្នុងការទិញឱសថ។

**មាត្រា៥៩.-**

នៅចំពោះមុខគ្រោះអាសន្នដែលមានអ្នកជំងឺ ឬអ្នករបួស ឬអ្នករងគ្រោះដោយថាហេតុ ឱសថការីត្រូវយកអស់មធ្យោបាយនិងការយល់ដឹងរបស់ខ្លួនជួយអ្នកទាំងនោះ តាមការដែលអាចធ្វើទៅបាន។

**មាត្រា៦០.-**

ឱសថការីត្រូវរួសរាយរាក់ទាក់ចំពោះអ្នកជំងឺនិងអតិថិជន ស្តាប់យោបល់ឬសំណូមពររបស់អ្នកទាំងនោះ និងត្រូវសម្រួលឱ្យមានការសន្ទនាបែបលាក់បាំង ព្រមទាំងរក្សាការសម្ងាត់របស់អ្នកជំងឺ។ សេចក្តីពន្យល់របស់ឱសថការីទៅអ្នកជំងឺនិងអតិថិជនត្រូវប្រាកដប្រជា ត្រឹមត្រូវ មិនហួសហេតុ និងងាយយល់។

**មាត្រា៦១.-**

ឱសថការីត្រូវរក្សាការសម្ងាត់ក្នុងវិជ្ជាជីវៈ ដោយគោរពសីលធម៌ គោរពសេចក្តីអៀនខ្មាសនិងការសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នកជំងឺ។

ឱសថការីមិនត្រូវនិយាយការសម្ងាត់ដែលខ្លួនបានដឹងឬបានឃើញពាក់ព័ន្ធនឹងរោគវិនិច្ឆ័យឬវេជ្ជបញ្ជា ឬឯកសាររបស់អ្នកជំងឺ ចំពោះមុខតតិយជនឬសាធារណជនឡើយ លើកលែងតែច្បាប់អនុញ្ញាតឬតម្រូវឱ្យបង្ហាញអាថ៌កំបាំង។

**មាត្រា៦២.-**

ឱសថការីត្រូវខិតខំធ្វើយ៉ាងណាឱ្យអ្នកជំងឺទទួលបាននូវអត្ថប្រយោជន៍ខាងសុខភាព ដែលជាសិទ្ធិទូទៅរបស់ប្រជាជន។

**មាត្រា៦៣.-**

ឱសថការីអាចផ្តល់ឱសថដល់អ្នកជំងឺដែលខ្លួនយល់ថាសមស្របនឹងការព្យាបាល ប៉ុន្តែជានិច្ចកាលត្រូវប្រាប់អ្នកជំងឺឱ្យទៅពិគ្រោះជាមួយគ្រូពេទ្យ។

**មាត្រា៦៤.-**

ឱសថការីត្រូវធ្វើយ៉ាងណាកុំឱ្យគេស្គាល់ភិនភាគឬអត្តសញ្ញាណរបស់អ្នកជំងឺ នៅពេលដែលខ្លួនធ្វើការផ្សព្វផ្សាយឬធ្វើបទបង្ហាញជាសាធារណៈ។

## ជំពូកទី៥
## ឱសថការីនិងសហភាគរៈ
## ឱសថការីនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត

**មាត្រា៦៥ .-**

ឱសថការីទាំងអស់ត្រូវមានទំនាក់ទំនងល្អជាមួយសហភាគរៈជានិច្ច និងត្រូវគោរពគ្នាទៅវិញទៅមកដោយប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីភាពស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ជៀសវាងការវាយប្រហារសហភាគរៈក្នុងបំណងប្រកួតប្រជែង។ ឱសថការីត្រូវចេះជួយសហភាគរៈទៅវិញទៅមកពេលមានទុក្ខលំបាក។

ក្នុងករណីដែលមានទំនាស់វិជ្ជាជីវៈរវាងសហភាគរៈ ត្រូវខិតខំសម្របសម្រួលដោយស្មារតីសាមគ្គីភាព។

**មាត្រា៦៦ .-**

ឱសថការីដែលគ្រប់គ្រងឱសថស្ថាន គ្រឹះស្ថានអាហារ័ណនីហារ័ណ គ្រឹះស្ថានផលិតឱសថ ត្រូវគាំទ្រ និងចាត់ទុកឱសថការីជំនួយការ ឬឱសថការីជំនួស ឬនិស្សិតឱសថសាស្ត្រឆ្នាំទី៥ជាសហភាគរៈ ដោយមិនមានការរើសអើងអ្វីឡើយ។

**មាត្រា៦៧ .-**

ឱសថការីត្រូវគោរពនិងរក្សាទំនាក់ទំនងល្អជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត ពិសេសបង្ហាញនូវកិច្ចសហការគ្នា ការផ្លាស់ប្តូរបទពិសោធ ការផ្តល់ព័ត៌មានដែលមានផលប្រយោជន៍ដល់សុខភាពមនុស្សក្នុងសង្គម។ ឱសថការីមិនត្រូវនិយាយឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ទោះបីជាសាធារណៈក្តី ជាឯកជនក្តី ដែលបង្កឱ្យមានការមិនសប្បាយចិត្តដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត។

**មាត្រា៦៨ .-**

ឱសថការីមិនត្រូវឃុបឃិតគ្នាជាមួយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត ដើម្បីទាញយកផលប្រយោជន៍ដោយផ្ទាល់ឬដោយប្រយោល ដែលនាំឱ្យមានបន្ទុកដល់អ្នកជំងឺឬក្រុមគ្រួសាររបស់អ្នកជំងឺឡើយ។

## ជំពូកទី៦
## ទណ្ឌកម្មខាងវិន័យ

**មាត្រា៦៩ .-**

ឱសថការីដែលមិនគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យពីគណៈឱសថការីកម្ពុជា។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៧០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧១ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៣២៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

## សម្រេច

**មាត្រា ១.-**

តែងតាំងមន្ត្រីរាជការចំនួន ០៤រូប ជាជំនួយការក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយករង :

១- លោក **សៀង ស៊ីវ៉េត**

២- លោក **ប្រាក់ សីហាឫទ្ធិ**

៣- លោក **ហាស់ សាខុន**

៤- លោកស្រី **តេង សារ៉ុន**

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៦៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ក្រសួងមហាផ្ទៃ ៖

១- លោកស្រីវរសេនីយ៍ទោ **រិត គន្ធា** អត្តលេខ ០៩៩៤៩

២- លោកវរសេនីយ៍ទោ **ស៊ុន ម៉ិនឡា** អត្តលេខ ១២៨០៤ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧៦ អនក្រ.បក**

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តសៀមរាប អាណត្តិទី៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្ដីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៧ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តសៀមរាបជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២២៥ អនក្រ.តត ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០១០ ស្ដីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តសៀមរាប
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **យុត វិត្យារិទ្ធ** បច្ចុប្បន្នជាអគ្គនាយករងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឱ្យបំពេញមុខងារជាអគ្គនាយករដ្ឋាករទឹកស្វយ័តសៀមរាប **អាណត្តិទី៣**។

**មាត្រា ២ :** អនុញ្ញាតជាគោលការណ៍បញ្ចូលក្របខ័ណ្ឌលោក **យុត វិត្យារិទ្ធ** ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលនឹងត្រូវបានកំណត់អំពីប្រភេទក្របខ័ណ្ឌ កាំប្រាក់បៀវត្សរបស់សាមីខ្លួន ដោយក្រសួងមុខងារសាធារណៈ ទៅតាមនីតិវិធីជាធរមាន។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល__ ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**    **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តសៀមរាប អាណត្តិទី៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០០៧ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តសៀមរាបជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## សម្រេច

**មាត្រា ១ :** តែងតាំងក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តសៀមរាប អាណត្តិទី៣ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. លោក | **តាន់ សុវិទ្យា** | តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២. លោក | **ប៉ែន វុត្ថា** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣. ឯកឧត្តម | **ខឹម វិសិដ្ឋ** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. ឯកឧត្តម | **ប៊ុន ថាវិទ្ធ** | តំណាងសាលាខេត្តសៀមរាប | សមាជិក |
| ៥. ឯកឧត្តម | **ហង់ ពៅ** | តំណាងអាជ្ញាធរអប្សរា | សមាជិក |

៦. កញ្ញា **ហ៊ូ ស៊ីនួន** តំណាងនិយោជិតរដ្ឋាករទឹកស្វយ័តសៀមរាប សមាជិក

៧. លោក **យុត វិត្យារិទ្ធ** អគ្គនាយករដ្ឋាករទឹកស្វយ័តសៀមរាប(អាណត្តិទី៣) សមាជិក

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ [illegible] ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៨ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយ ការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់មេដាយ **មាស ការងារ** ជូនដល់ក្រុមការងារ CCJAP ចំនួន ០២ នាក់ ដែលបានខិតខំប្រឹងប្រែងសហការក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ មានសុវត្ថិភាព» ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក ហួត | វេងចាន់ | ទីប្រឹក្សាគម្រោង CCJAP |
| ២-លោក ដួង | វណ្ណា | ទីប្រឹក្សាគម្រោង CCJAP |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា១ និងមាត្រា២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយស សហមេត្រី និង ស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ~**

ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **សហមេត្រី** និង **ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនលោកប្រធាន លោកនាយក និងសហការី នៃអង្គការមូលនិធិបង្ការរបួសអាស៊ី(AIPF) ចំនួន ១០ នាក់ ដែលបានខិតខំប្រឹងប្រែងអនុវត្តន៍បានល្អ និងបានគៀងគររកដៃគូអភិវឌ្ឍន៍នានា ក្នុងការអនុវត្តគម្រោងពាក់ព័ន្ធនឹងសុវត្ថិភាពចរាចរណ៍ផ្លូវគោកនៅកម្ពុជា ដោយចំណាយថវិកាសរុបចំនួន **៧៧៣,៩៧៤** ដុល្លារអាមេរិក(ប្រាំពីររយចិតសិបបីពាន់ ប្រាំបួនរយចិតសិបបួនដុល្លារអាមេរិកគត់) ដូចមានរាយនាមខាងក្រោម៖

**ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ ធិបឌិន្ទ**

-Mr. Greig Floyd Craft ប្រធាន អង្គការមូលនិធិបង្ការរបួស អាស៊ី
(The President of Asia Injury Prevention Foundation)

**ខ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ សេនា**

១-Ms. Mirjam Sidik នាយកប្រតិបត្តិ អង្គការមូលនិធិបង្ការរបួស អាស៊ី
(Executive Director of Asia Injury Prevention Foundation)

២-Mr. Saul Billing Sley អគ្គនាយករង អង្គការមូលនិធិ FIA
(Deputy Director General of Federation International de l'Automobile)

៣-Mr. Devid Sleet បុគ្គលិកជាន់ខ្ពស់នៃមជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជម្ងឺឆ្លង សហរដ្ឋអាមេរិក (Supreme Staff of Centers of Disease Control and Prevention)

៤-Ms. Michell Yeoh ឯកអគ្គរដ្ឋទូតសុឆន្ទៈសុវត្ថិភាពចរាចរណ៍សកល (Ambassador of Global Road safety)

**គ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ អស្សឫទ្ធិ**

-Ms. Madeleine Carr ទីប្រឹក្សាផ្នែកគាំទ្រមតិ និងផែនការយុទ្ធសាស្ត្រ អង្គការមូលនិធិបង្ការរបួស អាស៊ី ប្រចាំកម្ពុជា (Advocacy & Strategic Planning Advisor)

**ឃ-គ្រឿងឥស្សរិយយស ស្ថាបនាជាតិ ថ្នាក់ មាស**

-លោក គឹម បញ្ញា នាយកអង្គការមូលនិធិបង្ការរបួស អាស៊ី ប្រចាំកម្ពុជា

**ង-គ្រឿងឥស្សរិយយស ស្ថាបនាជាតិ ថ្នាក់ ប្រាក់**

១-លោក ស៊ឹម សុផល ប្រធានគ្រប់គ្រងកម្មវិធី អង្គការមូលនិធិបង្ការរបួស អាស៊ី ប្រចាំកម្ពុជា

២-លោក អ៊ឹម ពិសិដ្ឋ មន្ត្រីសម្របសម្រួល អង្គការមូលនិធិបង្ការរបួស អាស៊ី ប្រចាំកម្ពុជា

**ច-គ្រឿងឥស្សរិយយស ស្ថាបនាជាតិ ថ្នាក់ សំរិទ្ធ**

-លោកស្រី វ៉ុធ សិលា ជំនួយការហិរញ្ញវត្ថុ អង្គការមូលនិធិបង្ការរបួស អាស៊ី ប្រចាំកម្ពុជា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា១ និងមាត្រា២*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ចំនួន ១២ រូប របស់ក្រសួង ចំនួន ២ ទៅក្នុងឋានន្តរស័ក្តិក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|
| **ក្រសួងទេសចរណ៍ តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ តទៅ** | | | |
| ១ | លោក **ភាំង សុខចំរើន** | ក្រមការ | ថ្នាក់លេខ **១៤** |

| | | | |
|---|---|---|---|
| ២ | លោក ជោត ច័ន្ទណា | ក្រុមការ | ថ្នាក់លេខ ១៤ |
| ៣ | លោក មើក ភូសេម | ក្រុមការ | ថ្នាក់លេខ ១៤ |
| ៤ | លោក ហ៊ុយ សារ៉ាត់ | ក្រុមការ | ថ្នាក់លេខ ១៤ |
| ៥ | លោកស្រី អាន សុភាព | ក្រុមការ | ថ្នាក់លេខ ១៤ |
| ៦ | លោកស្រី មុត សុតី | ក្រុមការ | ថ្នាក់លេខ ១៤ |
| ៧ | លោកស្រី អ៊ាន់ រស្មី | ក្រុមការ | ថ្នាក់លេខ ១៤ |
| ៨ | លោកស្រី ខ៉ែត ស៊ីណែត | ក្រុមការ | ថ្នាក់លេខ ១៤ |
| ៩ | លោក លី បូតា | ក្រុមការ | ថ្នាក់លេខ ១៤ |
| ១០ | លោកស្រី បាន សុធីតា | ក្រុមការ | ថ្នាក់លេខ ១៤ |
| **ក្រសួងយុត្តិធម៌ តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៣ តទៅ** | | | |
| ១១ | លោក ជា ស៊ីបូរ៉ាមី | ក្រុមការ | ថ្នាក់លេខ ១១ |
| ១២ | លោកស្រី ហៃមុនី ធីរៈសុធីតា | ក្រុមការ | ថ្នាក់លេខ ១១ |

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតនេះទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ចំនួន ១៧ រូប របស់ក្រសួង ចំនួន ២ ទៅក្នុងឋានន្តរស័ក្តិក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការ និងក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសមធ្យមនៃក្របខ័ណ្ឌមន្ត្រីបច្ចេក-ទេសមធ្យម ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|
| **ក្រសួងបរិស្ថាន** | | | |
| **តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១២ តទៅ** | | | |
| ១ | លោក **គុយ គឿន** | ក្រមការ | ថ្នាក់លេខ ១២ |
| ២ | លោក **គល់ សម្បត្តិ** | ក្រមការ | ថ្នាក់លេខ ១២ |
| **តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ តទៅ** | | | |
| ៣ | លោក **ខុន ឈុនណា** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៤ | លោក **ស៊ីន រតនា** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៥ | លោក **ឈាន ចន្នី** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| **តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៣ តទៅ** | | | |
| ៦ | លោក **ម៉ែន ចិសិទ្ធ** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៧ | លោក **វឿន ជុំរុំ** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | |
| **តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៣ តទៅ** | | | |
| ៨ | លោកស្រី **ផេង ពិសី** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៩ | លោក **ហ៊ឹម សំបូរ** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១០ | លោក **ខាត់ សុចន្ទ** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១១ | លោក **អ៊ូម បណ្ឌិត** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១២ | លោក **កែវ ពិសិដ្ឋ** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១៣ | លោក **ជុន សីហា** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១៤ | លោកស្រី **ម៉ម សុគន្ធា** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ១៥ | លោកស្រី **ជិន លីដា** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |

| | | | |
|---|---|---|---|
| ១៦ | លោកស្រី **អ៊ីខ ម៉ាលិស្សា** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |
| ១៧ | លោក **និត្យ សុភាព** | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ **១៤** |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតនេះទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ ជូនលោកស្រី **ខា សារ៉េត** ទៅក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ១១ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម នៅក្រសួងសុខាភិបាល ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១២ តទៅ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៤៣ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកិច្ចការនារី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## សម្រេច

**មាត្រា ១.-** ត្រូវបានតែងតាំង លោក **ចៀម គឹមហួ** ជាជំនួយការលោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ

និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី *២៧* ខែ *មករា* ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៤ . អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

# សម្រេច

**មាត្រា ១.-** ត្រូវបានដំឡើងឋានន្តរស័ក្តិ លោក **យន ទ្រី** ពីឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តម ថ្នាក់លេខ **១១** ទៅឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ **១០** នៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម របស់ក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៤ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តកំពង់ធំ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ ថោង ខុន | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២. ឯ.ឧ សុក ផេង | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣. ឯ.ឧ ធីយ ឿន | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | សមាជិក |
| ៤. លោកជំទាវ ហ៊ុន ស៊ីណាត | អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៥. ឯ.ឧ ឡុង ផល | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦. ឯ.ឧ រស់ សីលវ៉ា | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. ឯ.ឧ មាន សុភា | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨. ឯ.ឧ សាមីឌី ស៊ីវឌ្ឍនា | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩. ឯ.ឧ កែវ បូរេន្ទ្រ | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១០. ឯ.ឧ ទា ច័ន្ទលីដា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១. ឯ.ឧ គឹម សន្តិភាព | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១២. ឯ.ឧ យឹម យ៉ាន់ | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៣. ឯ.ឧ ឈួន វៃ | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤. ឯ.ឧ ហ៊ី វីរៈ | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥. ឯ.ឧ សេង សុមុនី | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ១៦. ឯ.ឧ អ៊ឹង កុសល | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៧. ឯ.ឧ យិន ងួនក្ញលេនីន | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៨. លោកជំទាវ សួស រដ្ឋាវី | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៩. ឯ.ឧ លេង ផាលី | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ២០. ឯ.ឧ ទុន លាន | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ២១. លោកជំទាវ យុន រ៉ាវី | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២២. លោកជំទាវ ញ៉ែម មរកត | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ២៣. តំណាងក្រសួងការពារជាតិ | | សមាជិក |
| ២៤. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | | សមាជិក |
| ២៥. តំណាងក្រសួងព័ត៌មាន | | សមាជិក |
| ២៦. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ២៧. តំណាងក្រសួងបរិស្ថាន | | សមាជិក |
| ២៩. តំណាងក្រសួងមុខងារសាធារណៈ | | សមាជិក |
| ៣០. តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តកំពង់ធំ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

ទីស្តីការគណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម*
*លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៥ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តកំពត** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ ចម ប្រសិទ្ធ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២. ឯ.ឧ ចាយ សាំងយុន | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៣. ឯ.ឧ ប៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. ឯ.ឧ ជាច់ យន | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៥. ឯ.ឧ កែវ រ៉េមី | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. ឯ.ឧ ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៧. ឯ.ឧ ឈឹម ជួន | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៨. ឯ.ឧ ម៉ាន សុគ្រី | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩. ឯ.ឧ វ៉ាន់ ស៊ីវឿន | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០. ឯ.ឧ ហោ ដារិទ្ធ | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១១. ឯ.ឧ លឹម ឆាយ | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១២. ឯ.ឧ អ៊ឹម ចំរុង | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៣. ឯ.ឧ គួច វែងស្រ៊ុន | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤. ឯ.ឧ អ៊ីវ ផល្លី | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៥. ឯ.ឧ ញ៉ែម សូភឿន | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១៦. ឯ.ឧ អ៊ុន សុង | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧. ឯ.ឧ អ៊ុង វិបុល | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ១៨. លោកជំទាវ កែវ ចរិយា | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៩. លោកជំទាវ ខៀវ សុជានី | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២០.លោកជំទាវ ច្រឹង បុទុមរង្សី | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២១.លោកជំទាវ ទេស ច័ន្ទសារឿន | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ២២.លោកជំទាវ ព្រំ សុភី | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ២៣. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ២៤. តំណាងក្រសួងមុខងារសាធារណៈ | | សមាជិក |
| ២៥. តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | សមាជិក |
| ២៦. តំណាងក្រសួងទេសចរណ៍ | | សមាជិក |
| ២៧. តំណាងក្រសួងរ៉ែ និងថាមពល | | សមាជិក |
| ២៨. តំណាងក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ២៩. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តកំពត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៧ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តបន្ទាយមានជ័យ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ កែ គឹមយ៉ាន | ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ប្រធាន |
| ២. ឯ.ឧ សោ៊ី គុសល | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | អនុប្រធាន |
| ៣. ឯ.ឧ សុន គន្ធរ | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៤. ឯ.ឧ សន ស៊ីថន | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៥. ឯ.ឧ យូន រ៉ានីន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦. ឯ.ឧ សាបូ អូហ្សាណូ | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៧. ឯ.ឧ ហ៊ុយ ហានសុង | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៨. ឯ.ឧ សួន រចនា | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩. ឯ.ឧ ជូ យិនស៊ីម | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០. លោកជំទាវ រស់ សុវក្ខា | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១១.ឯ.ឧ ទិត ចន្ថា | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២. ឯ.ឧ លេង វី | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១៣. លោកជំទាវ ម៉ុម ថានី | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៤. ឯ.ឧ លី ស៊ីមអ៊ាម | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥. លោកជំទាវ នេត្រ ភូមារី | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៦. លោកជំទាវ យ៉យ នីតា | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ១៧. ឯ.ឧ ថាវ គឹមឡុង | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៨. ឯ.ឧ សុខ ភាព | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១៩. ឯ.ឧ ចែម វិឌ្ឍ៉ា | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២០. ឯ.ឧ វង់ សណ្តាប់ | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សរអោជិក |
| ២១. ឯ.ឧ ហ្វូត ហាក់ | អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២២. ឯ.ឧ សារាយ ធុន | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ២៣. តំណាងក្រសួងយុត្តិធម៌ | | សមាជិក |
| ២៤. តំណាងក្រសួងអប់រំ យុវជន និងកីឡា | | សមាជិក |
| ២៥. តំណាងក្រសួងព័ត៌មាន | | សមាជិក |
| ២៦. តំណាងក្រសួងមុខងារសាធារណៈ | | សមាជិក |
| ២៧. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ២៨. តំណាងក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ២៩. តំណាងក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| ៣០. តំណាងក្រសួងរ៉ែ និងថាមពល | | សមាជិក |
| ៣១. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*<u>កន្លែងទទួល:</u>*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តពោធិ៍សាត់** ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯ.ឧ ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | ប្រធាន |
| ២. ឯ.ឧ ច័ន្ទ តានី | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣. លោកជំទាវ ខៀវ បូរី | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៤. ឯ.ឧ ប៉ូល ពីឌូ | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ៥. ឯ.ឧ ហេង ហាក់ | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៦. លោកជំទាវ ម៉ាលី សុជាតា | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៧.លោកជំទាវ គ្រុយ លាងស៊ីម | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៨. លោកជំទាវ ឡូ គីម | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ៩. ឯ.ឧ សួង ម៉េងគា | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០. ឯ.ឧ ចាន់ សុវុឌ្ឍ | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១. ឯ.ឧ សាន វិសាល | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២. ឯ.ឧ វ៉េង សុធី | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. ឯ.ឧ នុត ច័ន្ទសុខា | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤. ឯ.ឧ ប៊ូ ជុំសេរី | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥. ឯ.ឧ ប៊ិន សម្បត្តិថាវ័ត្ត | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៦. ឯ.ឧ ស៊ូ សុវុធ | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៧. ឯ.ឧ ហាក់ សុខមករា | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៨. ឯ.ឧ ថាច់ កេត | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៩. ឯ.ឧ សេង សុវណ្ណារ៉ា | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ២០. ឯ.ឧ យី មៅ | អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២១. ឯ.ឧ មាស ម៉ូនីកា | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២២. ឯ.ឧ គង់ កន្តារ៉ា | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២៣. ឯ.ឧ ហោ សារុន | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៤. ឯ.ឧ ហាក់ ប៊ុនធឿន | អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ២៥. ឯ.ឧ ឡេង សែ | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៦. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | សមាជិក |
| ២៧. តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | សមាជិក |
| ២៨. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តពោធិ៍សាត់ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម*
*លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តឧត្តរមានជ័យ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ **នាយឧត្តមសេនីយ៍ គន់ គីម** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ | ប្រធាន |
| ២. ឯ.ឧ **នាយឧត្តមសេនីយ៍ ជា តារា** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ៣. ឯ.ឧ **ខឹម វិសិដ្ឋ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. ឯ.ឧ **ពេជ្រ សម្បត្តិ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. ឯ.ឧ **អ៊ិច ប៉ូកា** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៦. ឯ.ឧ **សៀក វណ្ណា** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧. ឯ.ឧ **ទៀវ សុគន្ធ** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៨. ឯ.ឧ **មាស ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៩. ឯ.ឧ **ឈូ អ៊ីម៉េង** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០. ឯ.ឧ **ផែង សុវិជ្ជានោ** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១១. ឯ.ឧ **បូ សុភាព** | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១២. ឯ.ឧ **ឡៅ ឈីវអ៊ាវ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

១៣. តំណាងក្រសួងមហាផ្ទៃ សមាជិក
១៤. តំណាងក្រសួងកិច្ចការនារី សមាជិក
១៥. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
១៦. តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក
១៧. តំណាងក្រសួងមុខងារសាធារណៈ សមាជិក
១៨. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១៩. តំណាងក្រសួងយុត្តិធម៌ សមាជិក
២០. តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
២១. តំណាងក្រសួងទេសចរណ៍ សមាជិក
២២. តំណាងក្រសួងធម្មការ និងសាសនា សមាជិក
២៣. តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
២៤. តំណាងក្រសួងធនធានទឹក និងឧតុនិយម សមាជិក
២៥. តំណាងក្រសួងរ៉ែ និងថាមពល សមាជិក
២៦. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
២៧. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
២៨. តំណាងក្រសួងបរិស្ថាន សមាជិក
២៩. តំណាងក្រសួងព័ត៌មាន សមាជិក

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តឧត្តរមានជ័យ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម*
*លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...១២៩...សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកោះកុង ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯ.ឧ កៅ ខុនដារ៉ា | អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ប្រធាន |
| ២. ឯ.ឧ មៀច សុផាន់ណា | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. ឯ.ឧ អាន ជាលី | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. ឯ.ឧ ហេង ចាន់ធួន | អនុរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៥. លោកជំទាវ នង យឿន | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៦. លោកជំទាវ ឡុង សុផល្លី | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ៧. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | | សមាជិក |
| ៨. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ៩. តំណាងក្រសួងទេសចរណ៍ | | សមាជិក |
| ១០. តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | សមាជិក |
| ១១. តំណាងក្រសួងអប់រំ យុវជន និងកីឡា | | សមាជិក |
| ១២. តំណាងក្រសួងផែនការ | | សមាជិក |
| ១៣. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ១៤. តំណាងក្រសួងបរិស្ថាន | | សមាជិក |
| ១៥. តំណាងក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |
| ១៦. តំណាងក្រសួងសុខាភិបាល | | សមាជិក |
| ១៧.តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ១៨. តំណាងក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ១៩. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ២០. តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | | សមាជិក |
| ២១.តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | | សមាជិក |
| ២២.តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | សមាជិក |
| ២៣.តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | សមាជិក |
| ២៤. តំណាងក្រសួងធម្មការ និងសាសនា | | សមាជិក |
| ២៥. តំណាងក្រសួងយុត្តិធម៌ | | សមាជិក |
| ២៦. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ២៧. តំណាងក្រសួងការពារជាតិ | | សមាជិក |
| ២៨. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | សមាជិក |
| ២៩. តំណាងក្រសួងមុខងារសាធារណៈ | | សមាជិក |
| ៣០. តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | | សមាជិក |

**ប្រការ២.-**

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រីថ្នាក់អគ្គនាយក អគ្គនាយករង ឬមន្ត្រីថ្នាក់ប្រហាក់ប្រហែលឲ្យចូលរួមក្នុងក្រុមការងារនេះ។

**ប្រការ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន រដ្ឋបាលខេត្តកោះកុង និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*

*-គ្រប់ក្រសួង ស្ថាប័ន*

*-រដ្ឋបាលថ្នាក់ក្រោមជាតិ*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៣០៨ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណង ដូចខាងក្រោម÷

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំតួនាទី និងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់នាយកដ្ឋាន និងអង្គភាព ក្រោមឱវាទអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើបេសកកម្មអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ។

**ប្រការ៥.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចដូចតទៅ÷

- រៀបចំការអនុវត្តច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- ពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋាន នាយកដ្ឋានជំនាញនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការផ្ទេរមុខងារនិងធនធាន ព្រមទាំងរៀបចំលិខិតបទដ្ឋាននានា សម្រាប់បម្រើដល់ការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមជាមួយអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំសារាចររបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំថវិកា និងអនុវត្តថវិកា
- សម្របសម្រួលជាមួយអង្គភាពនានា នៃក្រសួង ស្ថាប័ន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រួមចំណែកក្នុងការកៀរគរចំណូលពីប្រភពនានា ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន សម្រាប់រួមចំណែកដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- កសាងសមត្ថភាព ផ្តល់ការបណ្តុះបណ្តាល គាំទ្រដល់ការអនុម័តនិងការអនុវត្តថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រួតពិនិត្យ តាមដានការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដានលំហូរធនធានទៅក្នុងមូលនិធិនានា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីដៃគូអភិវឌ្ឍ និងសប្បុរជន
- សម្របសម្រួលជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ក្នុងការរៀបចំ អនុម័ត និងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៦.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ និងលេខាធិការដ្ឋាន ១ ដូចខាងក្រោម÷

- នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក
- នាយដ្ឋានគ្រប់គ្រងហិរញ្ញកិច្ចរដ្ឋបាល ឃុំ សង្កាត់
- លេខាធិការដ្ឋាន

នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួន តាមការចាំបាច់

អង្គការលេខរបស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៧.-**

- នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ

- លេខាធិការដ្ឋាននៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យ
- ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុវត្តប្រធានមួយចំនួនជាជំនួយការ។

## ជំពូកទី៣

## នាយកដ្ឋានគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស

**ប្រការ៨.-**

នាយកដ្ឋានគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស ដូចខាងក្រោម÷

- ចាត់ចែងរាល់លិខិតចេញ-ចូលនានា ដែលពាក់ព័ន្ធសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- ត្រួតពិនិត្យ តាមដាន និងដោះស្រាយនូវការប្រើប្រាស់មធ្យោបាយ សម្ភារៈទាំងអស់ ដែលបម្រើឱ្យកិច្ចប្រតិបត្តិការរដ្ឋបាលរបស់អគ្គនាយកដ្ឋាន
- ថែរក្សា និងតម្កល់ទុកដាក់ឯកសាររបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ និងសម្របសម្រួលការងារបណ្តុះបណ្តាលមន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ចាត់ចែង និងរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា
- ជាចំណុចប្រមូលផ្តុំនៃព័ត៌មានដែលទាក់ទិនទៅនឹងក្របខណ្ឌមន្ត្រីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បូកសរុបរបាយការណ៍នៃការរៀបចំផែនការថវិកា ការអនុវត្តថវិកា និងការសម្រេចទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រងបុគ្គលិក និងមន្ត្រីរាជការរួមរបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងតួលេខសរុបនៃចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិនិត្យមើលស្ថានភាពអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការជាមួយអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការអនុវត្តជាបណ្តើរៗការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យា
- សិក្សា និងរៀបចំគោលនយោបាយស្តីពីវិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុ
- រៀបចំឯកសារគតិយុត្តនានា ដើម្បីគាំទ្រដល់ការអនុវត្តថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ណែនាំការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងក្របខណ្ឌចំណាយរយៈពេលមធ្យម របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ជាសេនាធិការរបស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងឧបករណ៍វិនិយោគ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រង និងចាត់ចែងធនធានហិរញ្ញវត្ថុ សម្រាប់វិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- រៀបចំគោលការណ៍ណែនាំ និងការងារបច្ចេកទេសស្តីពីការអនុវត្តឧបករណ៍វិនិយោគ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សា និងផ្តល់អនុសាសន៍ពីគម្រោងវិនិយោគ របស់រដ្ឋបាលថ្នាក់ក្រោមជាតិនានា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលគ្រប់គ្រងឧបករណ៍វិនិយោគ របស់រដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យ និងអនុម័ត
- គ្រប់គ្រង និងធ្វើបញ្ជីសារពើភ័ណ្ឌសម្ភារៈការិយាល័យ និងគ្រឿងសង្ហារឹមទាំងអស់របស់អគ្គនាយកដ្ឋាន
- រៀបចំគម្រោងចំណាយថវិកាប្រចាំឆ្នាំ និងតម្រូវការមធ្យោបាយ សម្ភារៈ សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការរដ្ឋបាលរបស់អគ្គនាយកដ្ឋាន
- តាមដាន និងកត់ត្រារាល់សម្ភារៈរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងបញ្ជីគណនេយ្យរបស់អគ្គនាយកដ្ឋាន
- រៀបចំតារាងបើកបៀវត្ស និងសំណើសុំទូទាត់ថវិការបស់អគ្គនាយកដ្ឋាន
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៩.-**

នាយកដ្ឋានគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស មានការិយាល័យក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- ការិយាល័យគ្រប់គ្រងបុគ្គលិកនិងរដ្ឋបាល
- ការិយាល័យគ្រប់គ្រងទិន្នន័យនិងព័ត៌មានវិទ្យា
- ការិយាល័យគ្រប់គ្រងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ
- ការិយាល័យគ្រប់គ្រងឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការិយាល័យគ្រប់គ្រងគណនេយ្យ។

**ប្រការ១០.-**

ការិយាល័យគ្រប់គ្រងបុគ្គលិកនិងរដ្ឋបាល មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងបុគ្គលិក និងមន្ត្រីរាជការរួមរបស់អគ្គនាយកដ្ឋាន
- ចាត់ចែងរាល់លិខិតស្នាមនានា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋាន
- ត្រួតពិនិត្យ តាមដាន និងដោះស្រាយនូវការប្រើប្រាស់មធ្យោបាយ សម្ភារៈទាំងអស់ ដែលបម្រើឱ្យកិច្ចប្រតិបត្តិការរដ្ឋបាលរបស់អគ្គនាយកដ្ឋាន
- តម្កល់ទុកដាក់ និងថែរក្សាឯកសាររបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការ និងសម្របសម្រួលការងារបណ្តុះបណ្តាលមន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ចាត់ចែង រៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា
- ជាចំណុចប្រមូលផ្តុំនៃព័ត៌មានដែលទាក់ទិនទៅនឹងក្របខណ្ឌមន្ត្រីរាជការ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួលជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំអនុម័ត និងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បូកសរុប រៀបចំរបាយការណ៍អនុវត្ត និងរបាយការណ៍សម្រេចទូទាត់ថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១១.-**

ការិយាល័យគ្រប់គ្រងទិន្នន័យនិងព័ត៌មានវិទ្យា មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងតួលេខសរុបនៃចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ពិនិត្យមើលស្ថានភាពអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- រៀបចំការឧបត្ថម្ភកធនជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំការងារបូកសរុប និងកសាងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការជាមួយអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តជាបណ្តើរៗ នូវការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១២.-**

ការិយាល័យគ្រប់គ្រងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ÷

- សិក្សា និងរៀបចំគោលនយោបាយស្តីពីវិមជ្ឈការ និងវិសហមជ្ឈការហិរញ្ញវត្ថុ
- រៀបចំឯកសារគតិយុត្តនានា ដើម្បីគាំទ្រដល់ការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ណែនាំការរៀបចំ និងណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៣.-**

ការិយាល័យគ្រប់គ្រងឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទី និងភារកិច្ចដូចតទៅ÷

- ជាសេនាធិការរបស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រង និងចាត់ចែងធនធានហិរញ្ញវត្ថុសម្រាប់វិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំការបែងចែកធនធានហិរញ្ញវត្ថុសម្រាប់វិនិយោគជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំគោលការណ៍ណែនាំ និងការងារបច្ចេកទេសស្តីពីការអនុវត្តឧបករណ៍វិនិយោគ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សិក្សា និងផ្តល់អនុសាសន៍ពីគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានា ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលគ្រប់គ្រងឧបករណ៍វិនិយោគ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិនិត្យ និងអនុម័ត

- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៤.-**

ការិយាល័យគ្រប់គ្រងគណនេយ្យ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង និងធ្វើបញ្ជីសារពើភ័ណ្ឌសម្ភារៈការិយាល័យ និងគ្រឿងសង្ហារឹមទាំងអស់របស់អគ្គនាយកដ្ឋាន
- រៀបចំគម្រោងចំណាយ និងតម្រូវការមធ្យោបាយ សម្ភារៈ សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការរដ្ឋបាលរបស់អគ្គនាយកដ្ឋាន
- ត្រួតពិនិត្យ តាមដាន និងដោះស្រាយនូវការប្រើប្រាស់មធ្យោបាយសម្ភារៈទាំងអស់ ដែលបម្រើឱ្យកិច្ចប្រតិបត្តិការរដ្ឋបាលរបស់អគ្គនាយកដ្ឋាន
- តាមដាន និងកត់ត្រារាល់សម្ភារៈរបស់អគ្គនាយកដ្ឋាន
- កាន់កាប់បញ្ជីគណនេយ្យរបស់អគ្គនាយកដ្ឋាន
- រៀបចំតារាងបើកបៀវត្សរបស់អគ្គនាយកដ្ឋាន
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៤

## នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត

**ប្រការ១៥.-**

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោម÷

- សហការសម្របសម្រួល រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ របស់រដ្ឋបាលរាជធានី ខេត្ត ជាមួយគ្រប់ការិយាល័យពាក់ព័ន្ធនៃអគ្គនាយកដ្ឋាន
- ផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលរាជធានី ខេត្តក្នុងការរៀបចំ ការអនុម័ត និងការអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត
- តាមដានការអនុវត្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំរបាយការណ៍បូកសរុប ស្តីពីការអនុវត្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំផ្តល់ឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសជូនដល់រដ្ឋបាលរាជធានី ខេត្ត
- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងចំណូល របស់រដ្ឋបាលរាជធានី ខេត្ត
- តាមដានការអនុវត្តចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត
- តាមដានការអនុវត្តចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត

- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំផែនការថវិកាប្រចាំឆ្នាំជូនរដ្ឋបាលរាជធានី ខេត្ត
- សហការជាមួយគ្រប់ការិយាល័យពាក់ព័ន្ធ នៃអគ្គនាយកដ្ឋាន
- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំផ្តល់យោបល់លើសំណើសុំនិយ័តភាពថវិកា និងបន្ថែមឥណទានថវិកាជូនរដ្ឋបាលរាជធានី ខេត្ត
- សហការជាមួយគ្រប់ការិយាល័យពាក់ព័ន្ធនៃអគ្គនាយកដ្ឋាន
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៦.-**

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានី ខេត្ត មានការិយាល័យក្រោមឱវាទចំនួន ៣ដូចខាងក្រោម÷

- ការិយាល័យត្រួតពិនិត្យ និងតាមដានការអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត
- ការិយាល័យគ្រប់គ្រងចំណូល រដ្ឋបាលរាជធានី ខេត្ត
- ការិយាល័យគ្រប់គ្រងចំណាយ រដ្ឋបាលរាជធានី ខេត្ត។

**ប្រការ១៧.-**

ការិយាល័យត្រួតពិនិត្យ និងតាមដានការអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចដូចតទៅ÷

- សម្របសម្រួលរៀបចំលិខិតបទដ្ឋាន សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្ត
- ផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំ ការអនុម័ត និងការអនុវត្តថវិការដ្ឋបាលរាជធានី ខេត្ត
- តាមដានការអនុវត្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិការបស់រដ្ឋបាលរាជធានី ខេត្ត
- សម្របសម្រួលការធ្វើនិយ័ត និងការកែតម្រូវគម្រោងថវិការបស់រដ្ឋបាលរាជធានី ខេត្ត
- សម្របសម្រួលសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសជូនដល់រដ្ឋបាលរាជធានី ខេត្ត
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៨.-**

ការិយាល័យគ្រប់គ្រងចំណូលរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចដូចតទៅ÷

- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍គ្រប់គ្រងចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត
- តាមដានការអនុវត្តចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត

- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំផែនការថវិកាប្រចាំឆ្នាំជូនរដ្ឋបាលរាជធានី ខេត្ត
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ១៩.-**

កាិយាល័យគ្រប់គ្រងចំណាយរដ្ឋបាលរាជធានី ខេត្ត មានភារកិច្ចដូចតទៅ÷

- សិក្សានិងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងបទដ្ឋានចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត
- តាមដានការអនុវត្តចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត
- រៀបចំផ្តល់យោបល់លើសំណើបន្ថែម ឬចលនាឥណទានថវិការដ្ឋបាលរាជធានី ខេត្ត
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥

## នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក

**ប្រការ២០.-**

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក បំពេញមុខងារជាសេនាធិការឱ្យ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិលើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក ដូចខាងក្រោម÷

- សហការសម្របសម្រួល រៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក ជាមួយគ្រប់ការិយាល័យពាក់ព័ន្ធនៃអគ្គនាយកដ្ឋាន
- ផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលរាជធានី ខេត្ត ក្នុងការរៀបចំការអនុម័ត និងការអនុវត្តថវិការដ្ឋបាលក្រុង ស្រុក
- តាមដានការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំរបាយការណ៍បូកសរុប ស្តីពីការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំផ្តល់ឧបត្ថម្ភតុល្យភាពប្រចាំត្រីមាស ជូនដល់រដ្ឋបាលក្រុង ស្រុក
- រៀបចំបោះផ្សាយអាណត្តិ ផ្ទេរឥណទានពីគណនីថវិការដ្ឋ ទៅគណនីដោយឡែក របស់មូលនិធិក្រុង ស្រុក នៅរតនាគារជាតិ
- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រងចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក
- តាមដានការអនុវត្តចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក
- តាមដានការអនុវត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក

- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តចំណាយថវិកា របស់រដ្ឋបាលក្រុង ស្រុក
- រៀបចំផែនការថវិកាប្រចាំឆ្នាំជូនរដ្ឋបាលក្រុង ស្រុក
- សហការជាមួយគ្រប់ការិយាល័យពាក់ព័ន្ធនៃអគ្គនាយកដ្ឋាន
- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំផ្តល់យោបល់លើសំណើសុំនិយ័តភាពថវិកា និងបន្ថែមឥណទានថវិកាជូនរដ្ឋបាលក្រុងស្រុក
- សហការជាមួយគ្រប់ការិយាល័យពាក់ព័ន្ធនៃអគ្គនាយកដ្ឋាន
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២១.-**

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

- ការិយាល័យត្រួតពិនិត្យ និងតាមដានការអនុវត្តថវិការដ្ឋបាលក្រុង ស្រុក
- ការិយាល័យគ្រប់គ្រងចំណូលរដ្ឋបាលក្រុង ស្រុក
- ការិយាល័យគ្រប់គ្រងចំណាយរដ្ឋបាលក្រុង ស្រុក។

**ប្រការ២២.-**

ការិយាល័យត្រួតពិនិត្យ និងតាមដានរដ្ឋបាលក្រុង ស្រុក មានភារកិច្ចដូចតទៅ÷

- សម្របសម្រួលរៀបចំលិខិតបទដ្ឋានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- ផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលក្រុង ស្រុក ក្នុងការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក
- តាមដានការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តថវិការបស់រដ្ឋបាលក្រុង ស្រុក
- សម្របសម្រួលការកែតម្រូវគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក
- សម្របសម្រួលសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសជូនដល់រដ្ឋបាលក្រុង ស្រុក
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២៣.-**

ការិយាល័យគ្រប់គ្រងចំណូលរដ្ឋបាលក្រុង ស្រុក មានភារកិច្ចដូចតទៅ÷

- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍គ្រប់គ្រងចំណូលរបស់រដ្ឋបាលក្រុង ស្រុក
- តាមដានការអនុវត្តចំណូលរបស់រដ្ឋបាលក្រុង ស្រុក

- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តចំណូលរបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំផែនការថវិកាប្រចាំឆ្នាំជូនរដ្ឋបាលក្រុង ស្រុក
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២៤.-**

ការិយាល័យគ្រប់គ្រងចំណាយរដ្ឋបាលក្រុង ស្រុក មានភារកិច្ចដូចតទៅ÷

- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងបទដ្ឋានចំណាយរបស់រដ្ឋបាលក្រុង ស្រុក
- តាមដានការអនុវត្តចំណាយរបស់រដ្ឋបាលក្រុង ស្រុក
- រៀបចំផ្តល់យោបល់លើសំណើបន្ថែម ឬចលនាឥណទានថវិការដ្ឋបាលក្រុង ស្រុក
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តចំណាយរបស់រដ្ឋបាលក្រុង ស្រុក
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៦

## នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់

**ប្រការ២៥.-**

នាយដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាល ឃុំ សង្កាត់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ដូចខាងក្រោម÷

- សហការសម្របសម្រួលជាមួយនាយកដ្ឋានរដ្ឋបាល និងបច្ចេកទេសក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់ ជាមួយគ្រប់ការិយាល័យ ពាក់ព័ន្ធនៃអគ្គនាយកដ្ឋាន
- ផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលឃុំ សង្កាត់ ក្នុងការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់
- តាមដានការអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់
- រៀបចំរបាយការណ៍បូកសរុប ស្តីពីការអនុវត្តថវិកាឃុំ សង្កាត់
- រៀបចំបោះផ្សាយអាណត្តិផ្ទេរឥណទាន ពីគណនីថវិការដ្ឋ ទៅគណនីដោយឡែករបស់ មូលនិធិឃុំ សង្កាត់នៅរតនាគារជាតិ
- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍គ្រប់គ្រងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់
- តាមដានការអនុវត្តចំណូលថវិការដ្ឋបាលឃុំ សង្កាត់
- តាមដានការអនុវត្តចំណាយថវិការដ្ឋបាលឃុំ សង្កាត់
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តចំណូលថវិការដ្ឋបាលឃុំ សង្កាត់
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តចំណាយរដ្ឋបាលឃុំ សង្កាត់

- រៀបចំផែនការថវិកាប្រចាំឆ្នាំជូនរដ្ឋបាលឃុំ សង្កាត់
- សហការជាមួយគ្រប់ការិយាល័យពាក់ព័ន្ធ នៃអគ្គនាយកដ្ឋាន
- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងបទដ្ឋានចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់
- សហការជាមួយគ្រប់ការិយាល័យពាក់ពន្ធនៃអគ្គនាយកដ្ឋាន
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២៦.-**

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ មានការិយាល័យក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

- ការិយាល័យត្រួតពិនិត្យ និងតាមដានការអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់
- ការិយាល័យគ្រប់គ្រងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់
- ការិយាល័យគ្រប់គ្រងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់។

**ប្រការ២៧.-**

ការិយាល័យត្រួតពិនិត្យ និងតាមដានថវិការបស់រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចដូចតទៅ÷

- សម្របសម្រួលជាមួយនាយកដ្ឋានរដ្ឋបាល និងបច្ចេកទេស រៀបចំលិខិតបទដ្ឋានហិរញ្ញវត្ថុ របស់រដ្ឋបាលឃុំ សង្កាត់
- ផ្តល់ការគាំទ្រជាប្រចាំដល់រដ្ឋបាលឃុំ សង្កាត់ ក្នុងការរៀបចំ ការអនុម័ត និង ការអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់
- តាមដានការអនុវត្តថវិការបស់រដ្ឋបាលឃុំ សង្កាត់
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តថវិកាឃុំ សង្កាត់
- រៀបចំកាបត្តម្ភថវិកាប្រចាំត្រីមាសជូនរដ្ឋបាលឃុំ សង្កាត់
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២៨.-**

ការិយាល័យគ្រប់គ្រងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចដូចតទៅ÷

- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍គ្រប់គ្រងចំណូលរបស់រដ្ឋបាល ឃុំ សង្កាត់
- តាមដានការអនុវត្តចំណូលរដ្ឋបាលឃុំ សង្កាត់
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តចំណូលរដ្ឋបាលឃុំ សង្កាត់
- រៀបចំផែនការថវិកាប្រចាំឆ្នាំជូនរដ្ឋបាលឃុំ សង្កាត់
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ២៩.-**

កាវិយាល័យគ្រប់គ្រងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចដូចតទៅ÷

- សិក្សា និងផ្តល់អនុសាសន៍កែលម្អគោលការណ៍ និងបទដ្ឋានចំណាយរបស់រដ្ឋបាលឃុំ សង្កាត់
- តាមដានការអនុវត្តចំណាយរដ្ឋបាលឃុំ សង្កាត់
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តចំណាយរដ្ឋបាលឃុំ សង្កាត់
- បំពេញតួនាទី និងភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ ដោយមានការណែនាំពីអគ្គនាយក នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ជំពូកទី៧**

**លេខាធិការដ្ឋាន**

**ប្រការ៣០.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានតួនាទី និងភារកិច្ចដូចតទៅ÷

- ជាជំនួយការដល់អគ្គនាយក និងអគ្គនាយករងសម្រាប់ប្រតិបត្តិការងារប្រចាំថ្ងៃ
- សម្របសម្រួលការងារជាមួយអ្នកជំនាញការ ទីប្រឹក្សាជាតិ និងអន្តរជាតិ ក្នុងក្របខណ្ឌសមត្ថកិច្ចនៃអគ្គនាយកដ្ឋាន
- សម្របសម្រួលការអនុវត្តគម្រោងនានាដែលផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ សំដៅជួយគាំទ្រដល់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។
- សម្របសម្រួលជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ ក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**ជំពូកទី៨**

**អវសានប្បញ្ញត្តិ**

